## ខេត្តកណ្តាល

## សក្តានុពលវិនិយោគ

សីហា ឆ្នាំ ២០០៨




# ខេត្តកណ្តាល

## មជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា









USAID
ជំនួយពីពលរដ្ឋអាមេរិក

**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។




# របាយការណ៍វិនិយោគខេត្តកណ្ដាល


## បតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត ______ ២

## ចំណុចខ្លាំងរបស់ប្រទេស ______ ៣

បរិយាកាសអាជីវកម្មបើកចំហ
កំលាំងពលកម្មដែលមានតម្លៃទាប
ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

## តើហេតុអ្វីជ្រើសរើសយកខេត្តកណ្ដាល? ______ ៤

១. ទីតាំង
២. កំលាំងពលកម្ម - ច្រើនវ័យក្មេង មានការអប់រំ តម្លៃទាប
៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខគេ
៤. វិស័យសេវាកម្មហិរញ្ញវត្ថុដ៏ខ្លាំងក្លា
៥. វិស័យទេសចរណ៍
៦. ការផ្ដត់ផ្ដង់អគ្គិសនីផ្សេងៗ

## ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត ______ ៦

វិស័យទេសចរណ៍
ការផ្ដត់ផ្ដង់អគ្គិសនីផ្សេងៗ

## ឱកាសអាជីវកម្ម ______ ៦

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ ______ ៧

## ចង់ធ្វើការស្វែងយល់បន្ថែមទៀតទេ? ______ ៨


របាយការណ៍វិនិយោគនេះផលិតដោយ EMC សំរាប់គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។








# មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត

ដោយមានទីតាំងភូមិសាស្ត្រស្ថិតនៅព័ទ្ធជុំវិញរាជធានីរបស់ប្រទេស ខេត្តកណ្ដាលគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចមួយរបស់កម្ពុជា។ ខេត្តរបស់យើងគ្របដណ្ដប់លើទីតាំងជាច្រើនរបស់រោងចក្រកាត់ដេរសំលៀកបំពាក់ ដែលជាផ្នែកដ៏ធំបំផុតមួយនៃឧស្សាហកម្មរបស់កម្ពុជា ហើយខេត្តកណ្ដាលនេះក៏ជាទីតាំងរបស់រោងចក្រ និងសេវាពាណិជ្ជកម្មដ៏ច្រើនផងដែរ។ ទោះជាយ៉ាងណាក៏ដោយ យើងមានផលិតកម្មផ្សេងៗជាច្រើនទៀតក្រៅពីសំលៀកបំពាក់ និងស្បែកជើង។ ខេត្តរបស់យើងគឺជាអ្នកផលិតលើវិស័យកសិកម្មដ៏ចម្បង និងគឺជាទីកន្លែងពិសោធន៏សំរាប់ដំណាំកសិកម្ម និងមុខជំនួញទាំងឡាយដែលទាក់ទងនឹងវិស័យជលផល។

ខេត្តយើងក៏មានប្រជាពលរដ្ឋដែលមានវ័យក្មេង ពេញកំលាំងពលកម្ម មានការអប់រំល្អ និងឧស្សាហ៏ធ្វើការងារ ដែលជាកំលាំងពលកម្មដ៏ល្អបំផុតរបស់កម្ពុជា ហើយក៏ជាទីផ្សារដ៏ធំសំរាប់ជំនួញក្នុងស្រុកផងដែរ។

ផ្លូវទាំងឡាយដែលឆ្ពោះទៅកាន់ក្រុងភ្នំពេញ ឬក៏ចេញពីភ្នំពេញគឺឆ្លងកាត់ខេត្តកណ្ដាលដែលនេះជាការបញ្ជាក់យ៉ាងច្បាស់ថា ខេត្តរបស់យើងមានផ្លូវធំឆ្លងកាត់ខ្វាត់ខ្វែង ហើយមានហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតដូចជា ការផ្គត់ផ្គង់អគ្គិសនីជាដើម។ ដូចនេះខេត្តនេះក្លាយជាទីកន្លែងដ៏ល្អវិសេស សំរាប់បង្កើតមុខជំនួញផ្សេងៗ ពីព្រោះទីនេះជាមជ្ឈមណ្ឌលដែលផ្ដល់លទ្ធភាពគ្រប់បែបយ៉ាងសំរាប់ធ្វើជំនួញ។ ខេត្តនេះស្ថិតនៅជិតរាជធានីភ្នំពេញ ហើយយើងចំណាយពេលត្រឹមតែ ៤ ម៉ោងប៉ុណ្ណោះក្នុងការធ្វើដំណើរចេញពីកំពង់ផែសមុទ្រដ៏ជ្រៅនិងធំបំផុតរបស់កម្ពុជា ដែលមានទីតាំងនៅក្នុងក្រុងព្រះសីហនុ ហើយយើងក៏មានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាមផងដែរ ដែលអាចបង្កើតនូវពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិយ៉ាងងាយស្រួល និងមានប្រសិទ្ធភាព និងធ្វើឱ្យយើងអាចទទួលបានការប្រើប្រាស់អគ្គិសនីក្នុងតម្លៃថោក។

យើងមានក្ដីរំភើប អំពីសក្ដានុពលក្នុងការពង្រីក និងធ្វើឱ្យឧស្សាហកម្មរបស់យើងកាន់តែរីកចំរើនឡើងថែមទៀត ដោយយើងបានបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់ក្នុងការផ្ដល់ទុនទៅឱ្យតំបន់យុទ្ធសាស្ត្ររបស់យើង។ ដូច្នេះហើយ យើងសូមស្វាគមន៏ដោយបើកទូលាយចំពោះវិនិយោគិនថ្មីៗ ទាំងក្នុងស្រុក និងពីបរទេស។ យើងបានបង្កឱ្យមានលក្ខណៈងាយស្រួលដល់វិនិយោគិន ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងបើកដំណើរការអាជីវកម្មរបស់ខ្លួន។

ខ្ញុំសូមថ្លែងអំណរគុណដល់ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៏អន្តរជាតិដែលបានជួយឧបត្ថមក្នុងការរៀបចំបង្កើតរបាយការណ៏ វិនិយោគនិងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៏វិស័យឯកជននៅក្នុងខេត្តរបស់យើងខ្ញុំ។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយវិនិយោគិនទាំងអស់ ដើម្បីជួយធ្វើឱ្យពាណិជ្ជកម្មរបស់ពួកគេព្រមទាំងខេត្តដែលមានសក្ដានុពលរបស់យើងនេះ កាន់តែមានភាពរីកចំរើនឡើងថែមទៀត។

សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។



**ឯកឧត្តម ឈុន ស៊ីរុន**
អភិបាលខេត្តកណ្ដាល





## ចំណុចខ្លាំងរបស់ប្រទេស

ជាងមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានចេញមុខជាអ្នកប្រកួតប្រជែងក្នុងតំបន់ដ៏រឹងមាំ និងសកម្ម ដោយមានភោគទ្រព្យយ៉ាងសម្បូរបែប ដែលមានសារៈសំខាន់បំផុតសំរាប់កំណើន និងការអភិវឌ្ឍន៍អាជីវកម្ម ប្រកបដោយជោគជ័យ ។

### បើកទូលាយសំរាប់អាជីវកម្ម

- ពន្ធលើប្រាក់ចំណេញដែលមានតម្លៃទាប – ពន្ធ ២០% លើប្រាក់ចំណេញ ( ការខាតបង់ ៥ ឆ្នាំទៅមុខ)
- ពុំមានការកំណត់លក្ខខណ្ឌកាន់កាប់បរទេសទេ ។ ប្រទេសកម្ពុជាអនុញ្ញាតឱ្យមានសម្ព័ន្ធពាណិជ្ជកម្មរួមគ្នា ឬក្រុមហ៊ុនដែលកាន់កាប់ដោយបរទេសប្រតិបត្តិការ ១០០% ដោយមានសិទ្ធិពេញលេញ អាចនាំចូល និងនាំចេញផលិតផលបានស្ទើរគ្រប់ប្រភេទ ។
- វិនិយោគិនទាំងអស់ទទួលបានការការពារប្រកបដោយសមភាព ។
- ប្រទេសកម្ពុជាមានសេរីភាពខាងសេដ្ឋកិច្ចជាង ប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី [1] ។
- ពុំមានការគ្រប់គ្រងតម្លៃផលិតផល ឬសេវាណាមួយទេ ។
- ពុំមានការគ្រប់គ្រងការប្តូររូបិយប័ណ្ណបរទេស ឬការកំណត់ លក្ខខណ្ឌទៅលើការប្តូររូបិយប័ណ្ណនេះទេ ។
- ពុំមានការកំណត់លក្ខខណ្ឌស្តីអំពីការបង្វិលទុនទេ ។
- ជាសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក និង អាស៊ាន ។
- ពុំមានការកំណត់លក្ខខណ្ឌពាណិជ្ជកម្មបរិមាណ និង ពុំមានការទំលាក់ថ្លៃរបាំងពន្ធគយទេ ។ ប្រទេសកម្ពុជាអាចទទួលបានការលើកលែងពន្ធ និងការកំណត់កូតានៅលើទីផ្សារពិភពលោកធំៗ (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានជាច្រើនទៀត) ។
- អាជ្ញាធរខេត្ត មានសិទ្ធិអនុម័តការវិនិយោគទុនក្រោម ២ លានដុល្លារ ដើម្បីចាប់ផ្តើមអភិវឌ្ឍន៍អាជីវកម្មបានឆាប់រហ័ស ។

*" ប្រទេសកម្ពុជា បើកទូលាយយ៉ាងពេញលេញសំរាប់អាជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជានឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធានានូវបរិយាកាសគួរជាទីពេញចិត្តនិងជោគជ័យ ដល់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ "*

– សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន – នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

### កំលាំងពលកម្មដែលមានតម្លៃទាប

បើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែងក្នុងតំបន់ជាច្រើន ប្រទេសកម្ពុជារីករាយនឹងទទួលយកអត្រាប្រាក់ឈ្នួលទាបសមរម្យ ក្នុងគោលបំណងទាក់ទាញឧស្សាហកម្មដែលប្រើកំលាំងពលកម្មច្រើន ។

ឆ្លងកាត់រយៈកាលជាច្រើនឆ្នាំចុងក្រោយនេះ កំលាំងពលកម្មនៅប្រទេសកម្ពុជាបានកើនឡើងជាង ៥០% ដែលច្រើនជាងពីរដងនៃអត្រានៅក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀត[2] ។ ហើយដោយសារមានប្រជាជនវ័យក្មេងចំនួនច្រើន ( ចំនួនពាក់កណ្តាលមានអាយុក្រោម ២០ឆ្នាំ) ទើបធ្វើឱ្យកំណើននៃកំលាំងពលកម្មនេះ នឹងបន្តកើនឡើង ។

### ប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរ[3]

| ប្រទេស | អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោង (US$) |
|---|---|
| កម្ពុជា | 0.33 |
| ចិន | 0.88[a]/0.66[b] |
| ប៉ាគីស្ថាន | 0.41 |
| ឥណ្ឌា | 0.38 |
| ឥណ្ឌូនេស៊ី | 0.30 |
| បង់ក្លាដេស | 0.39 |

### ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅចំកណ្តាលតំបន់ ដែលមានសក្តានុពលបំផុតនៅលើពិភពលោក ។ ស្ថិតនៅចន្លោះប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាគឺ ជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងចេញពីទីក្រុងហូជីមិញ រហូតដល់ទីក្រុងបាងកក ។

ដោយសារទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជាបានរីករាយនឹងទទួលយកការគាំទ្រដ៏សំខាន់ពីសំណាក់អន្តរជាតិ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផល ពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃកំពុងតែរីកចម្រើនឡើងយ៉ាងឆាប់រហ័ស ។




*" អ្នកមានទីក្រុងធំជាងគេចំនួនពីរនៅក្នុងអាស៊ីតំបន់ដែលនៅអមប្រទេសអ្នក ។ អ្នកមានប្រជាជន ១៥ លាននាក់នៅទីក្រុងបាងកក និង ៨ លាននាក់ នៅទីក្រុងហូជីមិញ ហើយកំណើនផ្សេងៗមានការកើនឡើងជាលំដាប់នៅភាគកណ្តាលនៃទីក្រុងទាំងពីរ ។ "*

- Edward Hopkins, CB Richard Ellis Group Inc.

1. *The Heritage Foundation លិបិក្រមនៃសេរីភាពសេដ្ឋកិច្ច ឆ្នាំ២០០៨ ។ http://www.heritage.org/index/*
2. *ILO "និន្នាការសង្គម និងពលកម្មនៅក្នុងអាស៊ាន ឆ្នាំ ២០០៧ – សមាហរណកម្ម បញ្ហាប្រឈម និងឱកាស " ឆ្នាំ ២០០៧ ។*

3. *ចំណាំ: a) តំបន់ឆ្នេរ b) តំបន់ដីគោក*





# ហេតុអ្វីជ្រើសរើសយកខេត្តកណ្ដាល?

## ១. ទីតាំង

ដូចដែលគេតែងនិយាយនៅក្នុងការធ្វើអាជីវកម្ម, ទីតាំងអាជីវកម្មជាលក្ខខណ្ឌសំខាន់ជាងគេបំផុត ហើយខេត្តកណ្ដាលទទួលបានលក្ខខណ្ឌដ៏សំខាន់នេះ។ ខេត្តកណ្ដាលស្ថិតនៅក្បែររាជធានីរបស់ប្រទេសកម្ពុជា។ ខេត្តកណ្ដាលស្ថិតនៅជាប់ និង ព័ទ្ធជុំវិញទីក្រុងភ្នំពេញ។ ខេត្តកណ្ដាលអនុគ្រោះដល់អាជីវកម្មយ៉ាងល្អប្រសើរ ក្នុងការទទួលបានការផ្គត់ផ្គង់ ដៃគូ ទីផ្សារ និងភ្នាក់ងាររដ្ឋាភិបាលដ៏សំខាន់ៗ។

បច្ចុប្បន្ន ខេត្តកណ្ដាលបានក្លាយជាតំបន់ដ៏រឹងមាំ និងផុសផុលមួយ សម្រាប់ការស្វែងរកការធ្វើអាជីវកម្ម ដើម្បីគេចឱ្យផុតពីតម្លៃជួល និង តម្លៃដីថ្លៃខ្ពស់កប់ពពកនៅរាជធានីភ្នំពេញ ដែលតំបន់នេះទាញបានផលប្រយោជន៍ពីទីផ្សារធំ និងទីតាំងកណ្ដាល។

ខេត្តកណ្ដាលមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដ៏ប្រសើរ ដែលបំរើដល់ទីផ្សារទាំងក្នុង និងក្រៅប្រទេស។ ទន្លេធំៗចំនួនបួន ប្រវែង ២៦០ គ.ម ហូរកាត់ខេត្តកណ្ដាលផ្ដល់នូវធនធានធម្មជាតិយ៉ាងច្រើន និងឱកាសដឹកជញ្ជូនដ៏ប្រសើរ ។

ខេត្តកណ្ដាលមានផ្លូវជាតិចំនួន ១២ ខ្សែ មានប្រវែង ៤៤៦ គ.ម (១១% នៃប្រវែងផ្លូវរបស់ប្រទេសកម្ពុជាសរុប។ ជាលទ្ធផល ខេត្តកណ្ដាលមានផ្លូវជាតិ ដែលមានប្រវែងច្រើនគីឡូម៉ែត្រដែលក្នុងមួយគីឡូម៉ែត្រការ៉េ មានលើសផ្លូវជាតិទូទៅជាមធ្យម ៦ដង។

ផ្លូវជាតិលេខ ១ ចេញពីរាជធានីភ្នំពេញទៅដល់ទីក្រុងហូជីមិញ និងផ្លូវជាតិលេខ ៤ ចេញពីរាជធានីភ្នំពេញ ទៅដល់ក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់របស់ប្រទេសកម្ពុជា។ ផ្លូវជាតិទាំងនេះជាផ្នែកមួយនៃបណ្ដាញផ្លូវអាស៊ាន ដូច្នេះហើយទើបស្ថានភាពផ្លូវទាំងនេះមានលក្ខណៈល្អប្រសើរ។ ផ្លូវជាតិទាំងនេះ ជួយសម្រួលដល់ការដឹកជញ្ជូនបានយ៉ាងឆាប់រហ័សចេញពីខេត្តកណ្ដាលទៅកាន់ទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងប្រទេសវៀតណាម។ ជាលទ្ធផល អាជីវកម្មថ្មីៗ បានចាប់ផ្ដើមកើតមានព្រោងព្រាតនៅក្នុងខេត្តកណ្ដាល។

ស្ពានប្រវែង ២០ ម ថ្មីមួយនៅជ្រៃធំ នឹងតភ្ជាប់ពីខេត្តកណ្ដាលទៅប្រទេសវៀតណាម (ជាប់ទៅនឹង ចៅ ដុក) កាត់តាមផ្លូវជាតិលេខ ២១។ ស្ពាននេះ គេរំពឹងថា នឹងត្រូវសាងសង់ចប់សព្វគ្រប់នៅក្នុងឆ្នាំ ២០១០ ក្នុងគោលបំណងបង្កើនពាណិជ្ជកម្មតាមច្រកព្រំដែន។ នៅពេលស្ពាននេះ សាងសង់ចប់សព្វគ្រប់ ខេត្តកណ្ដាលនឹងមានផ្លូវហៃវេចូលទៅដល់កំពង់ផែប្រទេសវៀតណាម នៅ កាន់ ថូ។ រោងចក្រកាត់ដេរចំនួនពីរ បានប្ដូរទៅដាក់ទីតាំងនៅក្នុងតំបន់ព្រំដែនខេត្តកណ្ដាលនេះ ដែលមានដី និង កម្លាំងការងារក្នុងតម្លៃទាប។

**កម្ពុជា_ខេត្តកណ្ដាល រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុង បាងកក និងហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ។

## ២. កម្លាំងពលកម្ម - ច្រើនវ័យក្មេង មានការអប់រំខ្ពស់ តម្លៃទាប

ខេត្តកណ្ដាល គឺជាខេត្តមួយក្នុងចំណោមខេត្ត ដែលមានប្រជាពលរដ្ឋច្រើន គឺ ១,៣ លាននាក់។ ចំនួនប្រជាជនជាង ៤០% មានអាយុក្រោម១៨ឆ្នាំ–ទើបកំលាំងពលកម្មរបស់យើងមានវ័យក្មេងពេញចិត្តនឹងការងារ សម្រាប់ការងារច្រើនឆ្នាំខាងមុខដែលនឹងមកដល់។

### ប្រជាសាស្ត្រអនុគ្រោះ[4]




ក្រៅពីរាជធានីភ្នំពេញ ខេត្តកណ្ដាលមានអត្រាអក្ខរកម្មខ្ពស់ជាងគេ នៅក្នុងប្រទេសកម្ពុជា អត្រាចុះឈ្មោះចូលរៀនអនុវិទ្យាល័យមានកំរិតខ្ពស់ជាងសាលារៀនទូទៅគិតជាមធ្យម ។ ការចំណាយទៅលើការអប់រំនៅបឋមសិក្សា ដែលជាផ្នែកមួយនៃ ផលិតផលក្នុងស្រុក

4. *វិទ្យាស្ថានជាតិស្ថិតិ ជម្រឿនចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៤ ។*

# ហេតុអ្វីជ្រើសរើសយកខេត្តកណ្ដាល?





សរុប (GDP) បានកើនឡើងគួរឱ្យកត់សំគាល់នៅក្នុងប្រទេសកម្ពុជាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បន្ននេះមានកំរិតប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសថៃដែរ ។ ខេត្តកណ្ដាលមិនឈប់ត្រឹមនេះទេ ។ អាជ្ញាធរមានផែនការបន្តបង្កើនការចំណាយទៅលើការអប់រំបន្តទៀត ។

ដោយមានប្រព័ន្ធអប់រំប្រកបដោយប្រសិទ្ធភាពនោះ វាមិនគួរឱ្យភ្ញាក់ផ្អើលទេដែលកំលាំងពលកម្មខេត្តកណ្ដាលជាកំលាំងពេញវ័យ ទទួលការបណ្ដុះបណ្ដាលដើម្បីទ្រទ្រង់ពាណិជ្ជកម្មមិនមែនកសិកម្ម - ៤៦% នៃកម្លាំងពលកម្ម គឺជាអ្នកបំរើការនៅក្នុងរោងចក្រ និងវិស័យសេវានានា ( ហើយមានអត្រាខ្ពស់ជាងគេផងដែរក្រៅពីរាជធានីភ្នំពេញ) ។

យើងមានមោទនភាពណាស់ ដែលមានធនធានមនុស្សឈានមុខគេក្នុងការគាំទ្រអាជីវកម្មរបស់យើង ហើយជឿជាក់ថាការងារនេះជាឧត្តមភាពក្នុងការប្រកួតប្រជែងដ៏ខ្លាំងក្លាបំផុតមួយរបស់យើង - អនុញ្ញាតឱ្យប្រជាពលរដ្ឋយើងជួយធ្វើឱ្យសហគ្រាសរបស់អ្នកឱ្យកាន់តែមានភាពប្រសើរថែមទៀត ។

## ៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខ

ទីតាំងរបស់យើង បណ្ដាលឱ្យមានការបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួនពីរ (SEZs) នៅក្នុងខេត្តរបស់យើងផ្ទាល់ - តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់សេដ្ឋកិច្ចពិសេស ហ្គូហ្វេម ផាកស៊ុន Goldfame Pak Shun SEZ[5] ។

តំបន់សេដ្ឋកិច្ចពិសេសនៅរាជធានីភ្នំពេញ មានផ្ទៃដី ៣៥០ ហិចតា នៅតាមផ្លូវជាតិលេខ ៤ មានប្រវែង ៨គ.ម ចេញពីចំណតអាកាសយានដ្ឋានភ្នំពេញ និងមានប្រវែង ១៨គ.ម ចេញពីភាគកណ្ដាលទីក្រុងភ្នំពេញ ។ តំបន់សេដ្ឋកិច្ចពិសេសនេះ ត្រូវបានរំពឹងទុកថា នឹងអាចប្រើប្រាស់កម្មករបានច្រើនរហូតដល់ ១០០,០០០ នាក់ នៅចុងឆ្នាំ ២០១០ ។ តំបន់សេដ្ឋកិច្ចពិសេស Goldfame Pak Shun SEZ មានផ្ទៃដី ៨០ ហិចតា នៅក្នុងស្រុកស្អាង ។

តំបន់សេដ្ឋកិច្ចពិសេសទាំងនេះ ផ្ដល់នូវៈ

- ការផ្ដល់អាជ្ញាប័ណ្ណដែលមានប្រសិទ្ធិភាព ។
- ការិយាល័យរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនៅតាមច្រកព្រំដែនតែមួយ និងនៅក្នុងតំបន់ផ្ទាល់ សម្រាប់រាល់ការរត់ការ និង កិច្ចព្រមព្រៀង ។
- ក្រុមហ៊ុនមិនចាំបាច់បង់ពន្ធចន្លោះពេលពី ៣ ទៅ ៦ ឆ្នាំ ។
- លើកលែងពន្ធនាំចូលពេញលេញ ។
- ពុំមានពន្ធនាំចេញ ។
- ហេដ្ឋារចនាសម្ព័ន្ធថ្នាក់ពិភពលោក ។
- អគ្គិសនី ទឹក និង លូបង្ហូរទឹកស្អុយ និងប្រព្រឹត្តិកម្មទឹកកខ្វក់ ថោកជាង ១០% ។
- ដីឧស្សាហកម្មអាចជួលបានក្នុងតម្លៃសមស្រប ០.៥០ ដុល្លារ/ម$^{២}$ ក្នុងមួយខែ ។

វិនិយោគិននៅក្នុងតំបន់សេដ្ឋកិច្ចពិសេសផលិត និងនាំចេញសំលៀកបំពាក់ ទឹកបរិសុទ្ធ ប៉ូលអគ្គិសនី និងផលិតផលឧស្សាហកម្មធន់ស្រាលផ្សេងៗទៀត ។ ការវិនិយោគទុននៅក្នុងឧស្សាហកម្មផលិតមានគម្រោងផលិតកាតុង និងម៉ូទ័រ ។

## ៤. វិស័យសេវាកម្មហិរញ្ញវត្ថុដ៏ខ្លាំងក្លា

ដោយសារតែមានសហគមន៍អាជីវកម្មជួសជុលជាច្រើន និងប្រជាពលរដ្ឋថ្នាក់មធ្យមដែលកំពុងតែមានការរីកចំរើន វិស័យសេវាកម្មហិរញ្ញវត្ថុនៅក្នុងខេត្តកណ្ដាលមានការអភិវឌ្ឍន៍បានល្អប្រសើរ ។ ធនាគារពាណិជ្ជចំនួនពីរ មានសាខាទូទាំងខេត្តចំនួន ១៥ កន្លែង ។

យើងក៏មានជាង១០% នៃទីផ្សារមីក្រូហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាផងដែរ - អាជីវកម្មយើងទទួលបានដើមទុន ដែលគេត្រូវការដើម្បីធ្វើការពង្រីកបន្ថែម ។

## ៥. វិស័យទេសចរណ៍

ប្រជាជនក្នុងទីក្រុងភ្នំពេញជាច្រើន បានចាកចេញពីរាជធានី ដែលមានភាពក្ដៅហែង និងការកកស្ទះទៅរកទីជម្រកនៅក្នុងខេត្តរបស់យើង ដែលមានការទាក់ទាញដោយសម្រស់ធម្មជាតិ - ឆ្នេរទន្លេដែលសម្បូរដោយដីខ្សាច់ ផ្ដល់នូវនៅកន្លែងលំហែកាយដ៏មនោរម្យ ។ នៅក្នុងឆ្នាំ ២០០៧ ចំនួនភ្ញៀវទេសចរខត្តកណ្ដាល មានរហូតដល់ជិតមួយលាននាក់ ។

ការប្រមូលដើមទុនពីការរីកចំរើនផ្នែកសេដ្ឋកិច្ចរបស់ប្រទេសដែលកំពុងតែកើនឡើង ខេត្តកណ្ដាលក៏កំពុងស្វែងរកដើមទុនផងដែរ ដើម្បីអភិវឌ្ឍតំបន់បរិស្ថាន-ទេសចរណ៍ឱ្យបានច្រើនបន្ថែមទៀត ។ អាជ្ញាធរក្នុងតំបន់បានកំណត់ទីតាំងដែលជាតំបន់ទេសចរណ៍ចំនួន ៨កន្លែង

- ភ្នំព្រះរាជទ្រព្យក្នុងស្រុកពញាឮ
- ភ្នំប្រសិទ្ធិក្នុងស្រុកអង្គស្នួល និងស្រុកពញាឮ
- កោះដាច់ក្នុងស្រុកមុខកំពូល
- ស្អាងភ្នំក្នុងស្រុកស្អាង
- វត្តធនមន្តក្នុងស្រុកស្អាង
- វត្តកៀនស្វាយក្រៅក្នុងស្រុកកៀនស្វាយ
- វត្តអង្គរជ័យក្នុងស្រុកកៀនស្វាយ និង
- វត្តភ្នំរាបក្នុងស្រុកអង្គស្នួល

ខេត្តកណ្ដាល មានតំបន់ប្រវត្តិសាស្ត្រមួយចំនួន ដូចជា អង្គរជ័យ និង វត្តកៀនស្វាយក្រៅ ។ ខេត្តកណ្ដាលមានមណ្ឌលសិប្បកម្មមួយ ហើយអាជ្ញាធរមានបំណងលើកទឹកចិត្តដល់ផលិតកម្មនៃវត្ថុធាតុដើមធ្វើអំពីសូត្រ និងកែច្នៃនៅឃុំកោះដាច់ ។

យើងមានបំណងលើកទឹកចិត្តដល់វិនិយោគទុនផ្សេងៗ ផ្នែកឧស្សាហកម្ម សេវាសណ្ឋាគារ និងទេសចរណ៍ នៅក្នុងតំបន់របស់យើង ហើយអាជ្ញាធរ ខេត្តបានរៀបចំរួចជាស្រេច ក្នុងការសហការជាមួយនឹងវិនិយោគិនក្នុងគោលបំណងដើម្បីអភិវឌ្ឍវិស័យនេះជាមួយយើង ។

## ៦. ការផ្គត់ផ្គង់អគ្គិសនីផ្សេងៗ

ខេត្តកណ្ដាលបានទទួលការផ្គត់ផ្គង់អគ្គិសនីបានល្អប្រសើរ មកពីប្រភពមួយចំនួន រួមមានដូចជា ស្ថានីយ៍អគ្គិសនីចំនួន ២កន្លែងនៅក្នុងទីរួមខេត្ត និងស្ថានីយ៍អគ្គិសនីឯកជនក្នុងតំបន់ចំនួន ៤កន្លែងទៀត ។ ខេត្តកណ្ដាលក៏ទទួលបានការផ្គត់ផ្គង់អគ្គិសនីចេញមកពីភ្នំពេញ និងអគ្គិសនីដែលបាននាំចូលមកពីប្រទេសវៀតណាមផងដែរ ។

ការផ្គត់ផ្គង់អគ្គិសនីទូទាំងខេត្ត ត្រូវបានរំពឹងថាមានភាពប្រសើរ ដោយមានការនាំចូលពីប្រទេសវៀតណាម ដែលនឹងមានការកើនឡើងនៅរយៈពេលមួយឆ្នាំទៅពីរឆ្នាំទៀត ។

5. *តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនៅចន្លោះព្រំប្រទល់ទីក្រុងភ្នំពេញ និងខេត្តកណ្ដាល ។*





# ឧស្សាហកម្មសំខាន់ៗនៅក្នុងខេត្ត

## កសិកម្ម

ខេត្តកណ្តាលគឺជាខេត្តអំណោយទានផ្នែកកសិកម្ម។ ខេត្តនេះមានផ្ទៃដី សម្រាប់ធ្វើកសិកម្ម ចំនួន ១៤០,៧៩៧ ហិកតា។ ផ្ទៃដីធ្វើស្រែប្រហែល ១០១,៥០០ ហិកតា ផ្តល់ទិន្នផលលើស ទិន្នផលជាមធ្យមទូទាំងប្រទេស ។ដំណាំសំខាន់ផ្សេងទៀត មានដូចជា ពោត អំពៅ សណ្តែកសៀង បន្លែ និងផ្លែឈើផ្សេងៗទៀត។ ខេត្តកណ្តាល ផ្គត់ផ្គង់ត្រី សាច់ និងបន្លែទៅភ្នំពេញ និងទីផ្សារនាំចេញ ។

ខេត្តនេះក៏ផ្គត់ផ្គង់ទឹកត្នោតផ្អែមដល់ខុនហ្វ្រែល (Confirel)ដែលនាំចេញ ស្ករជាង ២០ តោនក្នុងមួយឆ្នាំ ។

មន្ទីរកសិកម្មខេត្តលើកកម្ពស់ការអនុវត្តកសិកម្មល្អ ដើម្បីធានាគុណភាព សុវត្ថិភាពនៃផលិតផលទាំងអស់ និងលើកកម្ពស់ការកែច្នៃក្រោយការប្រមូលផលសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ។ ការអប់រំប្រព័ន្ធកសិកម្មចំរុះជាលក្ខណៈគ្រួសារ ទទួលបានការលើកទឹកចិត្តឱ្យលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងគម្រោងអភិវឌ្ឍន៍កសិកម្មទាំងអស់ មន្ទីរកសិកម្មរៀបចំរួចជាស្រេចក្នុងការសហការជាមួយ ដៃគូអភិវឌ្ឍន៍ ដើម្បីជួយឱ្យខេត្តកណ្តាលក្លាយជាតំបន់កសិកម្មនាំមុខគេមួយនៅក្នុងប្រទេសកម្ពុជា។

ខេត្តកណ្តាល គឺជាខេត្តមួយក្នុងចំណោមខេត្តដែលមានឡូត៍នេសាទធំជាងគេក្នុងប្រទេសកម្ពុជា ដែលចាប់បានត្រីទឹកសាបប្រមាណប្រហែល ១៥% និង ប្រហែល ១០% សម្រាប់ផលិតផលវារីវប្បកម្មសរុប។

## ឧស្សាហកម្ម

ឧស្សាហកម្មកាត់ដេរនៅក្នុងខេត្តកណ្តាលមានច្រើនដាច់គេ ដែលមានឧស្សាហកម្មចំនួន ៦២ កន្លែង និងមានកម្មករចំនួន ៧០ ០០០ នាក់។

បន្ថែមលើវិស័យកាត់ដេរ យើងបានកសាងហេដ្ឋារចនាសម្ព័ន្ធផលិតដើម្បីគាំទ្រដល់វិស័យសំខាន់ៗផ្សេងទៀតរបស់យើងរួមមានដូចជា ផលិតកម្មស្បែកជើង ឡឥដ្ឋ និងគ្រឿង (ដើម្បីផ្គត់ផ្គង់ដល់ការរីកចំរើន ផ្នែកអចលនទ្រព្យនៅក្នុងរាជធានីភ្នំពេញ) និងឧស្សាហកម្មផ្នែកសេវាកម្មនានាជាច្រើននៅក្នុងប្រទេសកម្ពុជា។

រោងចក្រជីវៈអេតាណុលដំបូងនៅប្រទេសកម្ពុជា បានបង្កើតឡើងនៅខេត្តកណ្តាល។ ក្រុមហ៊ុនជីវថាមពល MH Bio-Energy Group និយាយថារោងចក្រនឹងផលិតប្រេងសម្រាប់ការនាំចេញ។ រោងចក្រនឹងត្រូវការចំការដាំដំឡូងមីក្នុងទំហំដី ៥០,០០០ ហិកតា ។

រោងចក្រប្រព្រឹត្តកម្មទឹកថ្មីមួយ ដែលចាប់ផ្តើមប្រតិបត្តិការនៅស្រុកកៀនស្វាយ ខេត្តកណ្តាល នៅខែសីហា ឆ្នាំ២០០៨។ រោងចក្រតំលៃ ២លានដុល្លាអាមេរិក នឹងផ្គត់ផ្គង់ទឹកដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានមានតម្លៃ ១,៧០០០ រៀលក្នុងមួយម៉ែត្រគូប ។

| សកម្មភាព | ចំនួនសហគ្រាស | ចំនួនកម្មករ |
|---|---|---|
| សំលៀកបំពាក់ សម្ភារៈពាក់លំអជើង និងវាយនភ័ណ្ឌ | 62 | ~70,000 |
| សេវាផ្សេងៗគ្នា រួមមាន ហិរញ្ញវត្ថុ សណ្ឋាគា និង បដិសណ្ឋារកិច្ចការអប់រំ ។ល។ | 31 | 23,181 |
| រោងពុម្ព | 2 | គ្មាន |
| សារធាតុគីមី | 2 | 150 |
| ការកែច្នៃឈើ | 2 | 100 |
| រោងចក្រផលិតឡាំង និងក្រដាស | 5 | 280 |
| ចំណីសត្វ | 1 | 132 |
| រោងចក្រជីវៈអេតាណុល | 1 | គ្មាន |
| ការបូមយកខ្សាច់ | 1 | គ្មាន |

អាជីវកម្មធុនតូច និងមធ្យម ជាច្រើនប្រតិបត្តិការក្នុងខេត្ត ដែលបានចុះ បញ្ជីធ្វើអាជីវកម្ម ២,០៥៨ កន្លែងនៅសាលាខេត្តរបស់យើង ។

សហគ្រាសអាជីវកម្មធុនតូច និងមធ្យមទាំងនេះ ជួលមនុស្សមកធ្វើការ ជាង ១១,៣០០ នាក់ ភាគច្រើនផ្នែកកែច្នៃម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ និង វត្ថុធាតុមិនធ្វើពីដែក ។

ចំនួនក្រុមហ៊ុនធំៗជាច្រើន បានផ្លាស់ប្តូរការិយាល័យរបស់ខ្លួនមកខេត្តកណ្តាលដើម្បីឱ្យបានជិតទៅនឹងផលិតកម្ម និងទទួលបានផលប្រយោជន៍ពីការចំណាយលើការធ្វើពាណិជ្ជកម្មថោកជាងនៅក្នុងរាជធានីភ្នំពេញ។ រោងចក្រនានា កំពុងប្តូរទៅដាក់ទីតាំងនៅជនបទនៃខេត្តកណ្តាល ដើម្បីទាញយកផលប្រយោជន៍ផ្សេងៗក្នុងតម្លៃទាប ដែលរួមមានអគ្គិសនីមកពីវៀតណាមដែលមានតម្លៃទាប ។

# ឱកាសអាជីវកម្ម

ខេត្តរបស់យើងផ្តល់ឱកាសជាច្រើនសំរាប់អាជីវកម្មថ្មីៗ ដែលបង្ហាញយ៉ាងច្បាស់ដោយក្រុមហ៊ុននានាជាច្រើនប្រភេទ ដែលបានប្រតិបត្តិការនៅទីនេះស្រាប់។ យើងមើលឃើញឱកាសសំខាន់ៗសំរាប់ពាណិជ្ជកម្ម ដើម្បីទាញយកកំលាំងប្រកួតប្រជែងតាមរយៈការវិនិយោគទុនបន្ថែមទៀតនៅក្នុងវិស័យ:

- **កសិ-ពាណិជ្ជកម្ម** ជាពិសេសការកែច្នៃចំណីអាហារ។ យើងមានឱកាសសំខាន់ក្នុងការបន្ថែមតម្លៃទៅលើទិន្នផលកសិកម្មយ៉ាងច្រើនផ្សេងៗគ្នា។ យើងមានឱកាសដាំដំណាំអំពៅ ពោត និងបន្លែ។ យើងក៏ឃើញមានសក្តានុពលល្អ ក្នុងការចិញ្ចឹមជ្រូកផងដែរ។






- **ការកែច្នៃសាច់ត្រី** អាជ្ញាធរខេត្តកណ្ដាលកំពុងស្វែងរកការវិនិយោគទុនបន្ថែមទៀតនៅក្នុងដំណើរការកែច្នៃសាច់ត្រី សម្រាប់ទីផ្សារនាំចេញ ហើយនឹងធ្វើការយ៉ាងជិតស្និតជាមួយនឹងវិនិយោគិន ក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដើម្បីទទួលបានផលប្រយោជន៍ពីគម្រោង និងអាជីវកម្មថ្មីនេះ។ ខេត្តនេះមានធនធានទឹកសំខាន់នៅក្នុងទន្លេ និងបឹងជាច្រើន។ យើងនឹងជួយដល់វិនិយោគិនផងដែរដោយផ្ដល់ជំនួយការខាងបច្ចេកទេស នាយកដ្ឋានវារីវប្បកម្ម និងកសិកម្ម ដើម្បីបង្កើនទិន្នផល និងផលិតភាពរបស់កសិករ។
- **ឧស្សាហកម្មធុនស្រាល** ឧស្សាហកម្មធុនស្រាល រួមមានដូចជា វិស័យកាត់ដេរ និងអេឡិចត្រូនិចជាដើម។ កំលាំងពលកម្មជាច្រើនដែលយកតម្លៃទាប ហេដ្ឋារចនាសម្ព័ន្ធ និងបរិយាកាសអាជីវកម្មអំណោយផល។ ស្រុកកោះធំ ដែលមានដី កម្លាំងការងារ និង អគ្គិសនីក្នុងតម្លៃទាប នឹងអាចចូលទៅដល់ប្រទេសវៀតណាមបានយ៉ាងស្រួល ព្រោះស្ពានជ្រៃធំនឹងបើកនៅឆ្នាំ ២០១០ ។
- **បរិស្ថាន-ទេសចរណ៍** ឱកាសមានសម្រាប់ការប្រមូលទុនពីការអភិវឌ្ឍន៍ឃុំកោះដាច់ ភ្នំធនមន្ត ភ្នំស្អាង និងទីតាំងផ្សេងៗទៀត។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

ទោះបីជាយើង មានមោទនភាពចំពោះស្នាដៃនានារបស់យើងក៏ដោយ ក៏យើងនៅតែពង្រឹង និងខិតខំទាក់ទាញផ្នែកវិនិយោគឱ្យកាន់តែមានភាពប្រសើរថែមទៀតដែរ។ យើងនៅតែសកម្មក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មរបស់យើង និងទាក់ទាញសហគ្រាសអាជីវកម្មឈានមុខគេឱ្យចូលមកខេត្តរបស់យើង។ ការអភិវឌ្ឍន៍សំខាន់ៗមួយចំនួននៅក្រោមវិធីសាស្ត្ររួមមានដូចតទៅ:

- យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មវិនិច្ឆ័យរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្រោមកម្មវិធីនេះ ផលិតផលនៅក្នុងខេត្តកណ្ដាល ជាច្រើនទទួលបានការគាំទ្របន្ថែមទៀត។ ផលិតផលដែលកំណត់អត្តសញ្ញាណដោយយុទ្ធសាស្ត្រនេះ រួមមានទាំង ឧស្សាហកម្មកាត់ដេរស្បែកជើង និងស្រោមជើង ឧស្សាហកម្មធុនស្រាល កៅស៊ូ នេសាទ ការដឹកជញ្ជូន។ ការជួយ រួមមានការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និងការផ្សព្វផ្សាយពាណិជ្ជកម្ម កំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាព គ្រប់គ្រង និងជំនាញក្នុងតំបន់ ។
- ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍន៍ វិស័យឯកជននៅក្នុងខេត្តកណ្ដាលក្នុងឧស្សាហកម្មសំខាន់ៗ:

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យកសិកម្ម |
|---|---|---|
| ការធ្វើឱ្យផលិតកម្មបន្លែ និង ប្រព័ន្ធគ្រប់គ្រងក្រោយពេលប្រមូលផលកាន់តែមានភាពប្រសើរឡើង | ACIAR | ផ្លែឈើ និង បន្លែ ម្ទេស |
| ការធ្វើឱ្យការយល់ដឹងនិងការគ្រប់គ្រងជម្ងឺស្រូវកាន់តែមានភាពប្រសើរឡើង | ACIAR | ដំណាំស្រូវ |
| គម្រោងពង្រីកកសិកម្មអូស្ត្រាលី-កម្ពុជា ដំហានទី II | AusAID | កសិកម្ម |
| គម្រោងកែលំអគុណភាពកសិកម្ម | AusAID | ស្រូវ ផ្លែឈើ និង បន្លែ |
| គម្រោងសេវាព័ត៌មានទីផ្សារកសិកម្ម | CIDA | ផ្លែឈើ និង បន្លែ |
| ការសិក្សាទៅលើការអភិវឌ្ឍន៍កសិកម្មដ៏ទូលំទូលាយអំពីអាងព្រែកត្នោត | JICA | ដំណាំស្រូវ |
| គម្រោងលើវិស័យធារាសាស្ត្រពាយព្យ | AFD | ធារាសាស្ត្រ |
| លើកកម្ពស់ និងកែលំអកសិកម្ម | WOB | កសិកម្ម |
| គម្រោងកាត់បន្ថយការប្រើប្រាស់សារធាតុគីមី | FAO | បន្លែ និងស្រូវ |
| ឃ្លាំងចំណេះដឹងផ្នែកស្រូវនៅកម្ពុជា | ADB | ស្រូវ |
| គម្រោងអភិវឌ្ឍន៍សហគមន៍ | Worl Vision | បសុសត្វ និងដំណាំ |
| ការកែលំអផលិតកម្ម និងការព្យាបាលគោក្របី | ACIAR | បសុសត្វ |
| គំរោងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និង ខ្នាតមធ្យម (MSME) | USAID | បសុសត្វ ត្រី ជ្រូក ការកែច្នៃផលិតផលកសិកម្ម ឡឥដ្ឋ-ក្បឿង |

## ចង់ធ្វើការស្វែងយល់បន្ថែមទៀតឬទេ?

សំរាប់ព័ត៌មានបន្ថែមស្តីអំពីឱកាសវិនិយោគ និងការអភិវឌ្ឍន៍នៅក្នុងខេត្តកណ្តាល សូមទាក់ទង:

ការិយាល័យ **ឯកឧត្តម នៃ ចារី**
អភិបាលរងខេត្តកណ្តាល
(855)12 220 606
អ៊ីម៉ែល: charey@camshin.com.kh ឬ

**លោក ប្រាក់ សារ៉ាត**
នាយរងខុទ្ទកាល័យ
(855)12 779 956

**លោក នុត សុង**
អគ្គលេខាធិការ
(855)12 932 667

**លោក សោម ជីវ័ន**
ប្រធានការិយាល័យសេដ្ឋកិច្ច
(855)11 715 705

**លោក សេក ស៊ីធួន**
មន្ទីរពាណិជ្ជកម្ម
(855)12 224 631

**លោក ហេង ផេនិច្ច**
ប្រធានមន្ទីរឧស្សាកម្ម
(855)12 836 332

**លោក ប៊ុនធួន ស៊ីម៉ូណា**
ប្រធានមន្ទីរកសិកម្មខេត្តកណ្តាល
(855)12 898 049

**លោក ផាង រតនៈ**
ប្រធានមន្ទីរទេសចរណ៍
(855)12 738 687

**លោក ខ្លាំង វ៉ាន់ធុល**
ប្រធានមន្ទីររុក្ខា ប្រម៉ាញ់ និងនេសាទ
(855)17 771 881

**www.cambodiainvestment.gov.kh**

**www.investincambodia.com**
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណៈកម្មការវិនិយោគកម្ពុជា
ទូរស័ព្ទ: (855) 23 981 154

**www.cambodianinvestment.gov.kh**

វិទ្យាស្ថានជាតិស្ថិតិ: www.nis.gov.kh

### ក្រសួងនានា

ក្រសួងពាណិជ្ជកម្ម:
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល:
www.mine.gov.kh
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:
www.mlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់:
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍:
www.mptc.gov.kh
ក្រសួងសាធារណការ និងដឹកជញ្ជូន:
www.mpwt.gov.kh
ក្រសួងទេសចរណ៍:
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:
www.maff.gov.kh

### ផ្សេងៗ

សមាគមឧស្សាហកម្មកាត់ដេរនៅកម្ពុជា
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល
www.cambodia-gpsf.org
សភាពាណិជ្ជកម្មភ្នំពេញ:
www.ppcc.org.kh
សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ:
www.smecambodia.org

| ស្ថានភាពទូទៅខេត្តកណ្តាល | |
|---|---|
| ចំនួនប្រជាជន: | 1,280,781 |
| អាយុពី 15-64:58,2% | |
| សមាមាត្រការងារក្នុងវិស័យកសិកម្ម: | 51% |
| លំដាប់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 2/24 |
| ផ្ទៃដី: | 3,568 km² |
| ដង់ស៊ីតេប្រជាជន:<br>(% ចំនួនប្រជាជនជាមធ្យម) | 452% |
| ចំនួនស្រុក: | 11 |
| ចំនួនឃុំ: | 147 |

| ស្ថានភាពដីក្នុងខេត្តកណ្តាល |
|---|
| ប្រភេទ: ភាគច្រើនដីប្រផេះល្បប់។ ស្ថិតនៅជាប់ដងទន្លេមេគង្គ ដែលមានដីប្រភេទល្បប់ពណ៌ត្នោត។ នៅភាគពាយព្យប្រទេស ជាទូទៅមានដីប្រភេទក្រហមលឿង។ |
| កម្រិតជីវជាតិ: មធ្យម |

| អត្រាពន្ធនៅកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាប្រាក់លើកទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអតិបរមា | | 1% ប្រាក់ចំណូល |
| ពន្ធហួតទុក | | 15% |
| ចំណូលបានមកពីការជួលអលនទ្រព្យ | | 10% |
| ការទូទាត់ចំពោះមនុស្សចំណូលស្រុក | | 14% |
| | | |
| ពន្ធលើប្រាក់ខែ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| មនុស្សចំណូលស្រុក | អត្រាថេរ | 20% |
| ពន្ធផលប្រយោជន៍បន្ទាប់បន្សំ | | 20% |
| តម្លៃបន្ថែមលើពន្ធ | | 10% |
| | នាំចេញ | 0% |
| ពន្ធផ្ទេរអចលនទ្រព្យ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា | 2005 | 2006 | 2007 | 2008f | 2009f |
|---|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 7.5 | 7.0 |
| កំណើននាំចេញ (%) | 12.6 | 19.2 | 8.1 | 5.6 | 8.5 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 65.7 | 66.1 |
| FDI ($m) | 375 | 475 | 598 | 660 | 759 |
| FDI (% GDP) | 6.0 | 6.5 | 6.9 | 6.7 | 6.8 |

## ចំណាយអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| ភ្នំពេញ | $350-$2,000 |
| ដីធ្វើអាជីវកម្ម | $30-$100 |
| តំបន់ផ្សេង | $4-$30 |
| ជនបទ | $0.50-$5 |
| **ដីសំរាប់ការិយាល័យ** | **តម្លៃជួលក្នុងមួយខែ** |
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| ប្រាក់ជួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ប្រាក់ជួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| តម្លៃពលកម្ម | ប្រាក់ខែ $ ក្នុងមួយខែ |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | 1,000-1,500 |
| អ្នកគ្រប់គ្រងកណ្តាល | 500-1,000 |
| អ្នកគ្រប់គ្រងកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ជំនួយការ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាមទ្វារ | 50-80 |
| កម្មករ | 50-80 |
| ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ | 60 |

| តម្លៃអគ្គិសនីនៅភ្នំពេញ (excl. SEZs) | | |
|---|---|---|
| ឧស្សាហកម្ម | គីឡូវ៉ាត់ម៉ោង/ខែ | តម្លៃ (រៀល/គីឡូវ៉ាត់) |
| | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | | $0.32/គ.ក្រ |

# ខេត្តកណ្ដាល

## សក្តានុពលវិនិយោគ



Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com